# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបើកសិក្ខាសាលាគ្រូអប់រំជំនឿ
# ភ្នំពេញថ្មីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៨
## *ជំនឿជាអំណោយទានដែលយើងទទួល*

អត្ថបទទី១៖ វវ ៤,១-១១
ដំណឹងល្អ៖ លក ១៩,១១-២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងនឹករឭកដល់បងប្រុសធារី ដែលជាជនជាតិអូស្ត្រាលីគាត់បានស្រាវជ្រាវសេចក្តីត្រូវការរបស់ប្រជាជនខ្មែរនៅឆ្នាំ១៩៩៧។ គាត់បានឃើញ ក្មេងពិការអត់មានឱកាសទៅសាលា ក្រោយមកគាត់ក៏បានសម្រេចចិត្តបង្កើតសាលាឡាវ៉ាឡានៅតាខ្មៅ។ ម្សិលមិញ គាត់បានទទួលមរណភាពនៅប្រទេសអូស្ត្រាលីដោយរោគាពាធ ដូច្នេះយើងអធិដ្ឋាននឹកឃើញដល់វិញ្ញាណក្ខន្ធរបស់គាត់នៅក្នុងអភិបូជានេះ និងជាពិសេសដល់កូនក្មេងពិការនិងលោកគ្រូអ្នកគ្រូនៅសាលាឡាវ៉ាឡាទាំងអស់។ សាលាឡាវ៉ាឡា ជាកន្លែងមួយពិសេសដែលយើងបង្កើតក្រុមគ្រួសារមួយដែលយើងចេះគោរពគ្នាទៅវិញទៅមក ចេះស្រឡាញ់គ្នាទៅវិញទៅមកទាំងកូនក្មេង ទាំងលោកគ្រូអ្នកគ្រូ ទាំងបុគ្គលិកទាំងអស់ជាមហាគ្រួសារមួយ ដែលបង្ហាញអំពីសញ្ញាសម្គាល់នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

ថ្ងៃនេះយើងគោរពដល់ឪពុកម្តាយព្រះនាងម៉ារី ដែលបានយកព្រះនាងម៉ារីទៅវិសាលវិហារយេរូសាឡឹម នៅពេលនោះលោកតាយ៉ូហានគីម និងលោកយាយហាណា បានសម្រេចចិត្តថ្វាយព្រះនាងម៉ារីទៅព្រះជាម្ចាស់។ នៅយប់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១២ មានការអស្ចារ្យមួយបានកើតឡើងនៅអរីយក្សត្រ មានលោកតាម្នាក់ដែលជាពុទ្ធបរិស័ទគាត់បានយល់សុបិនឃើញព្រះយេស៊ូដែលចង្អុលឲ្យគាត់ទៅដល់មាត់ទន្លេ ស្អែកឡើងគាត់ពិភាក្សាជាមួយប្រពន្ធរបស់គាត់អំពីការយល់សុបិននេះ។ យប់ថ្ងៃទី១៨ឡើងគាត់យល់សុបិនឃើញម្តងទៀត យប់ថ្ងៃទី១៩យល់សុបិនឃើញម្តងទៀត យប់ថ្ងៃទី២០យល់សុបិនឃើញម្តងទៀត ក្រោយមកប្រពន្ធរបស់គាត់ឲ្យទៅមើលនៅមាត់ទន្លេហ្នឹងមានអ្វី។ ក្រោយមក លោកតាគាត់បានឃើញរូបព្រះនាងម៉ារីពីរម៉ែត្រមួយតឹក ធ្វើដោយស្ពាន់ដែលមានកុមារយេស៊ូ ដែលនេះជារូបសំណាកព្រះនាងម៉ារីទីពីរដែលគេស្រង់ចេញពីទន្លេមេគង្គនៅអរីយក្សត្រ។ នេះជាការអស្ចារ្យមួយ ដែលណែនាំឲ្យយើងយល់ថាព្រះនាងម៉ារីពីដើមរៀងមកបានថែរក្សាព្រះសហគមន៍ និងក្រុមគ្រួសាររបស់យើងនៅប្រទេសកម្ពុជា។ ថ្ងៃនេះ យើងនឹកឃើញដល់ឪពុកម្តាយរបស់ព្រះនាងម៉ារី "**ជំនឿជាអំណោយទានដែលយើងទទួល**" ជំនឿនេះត្រូវតែថែរក្សាការពារនៅក្នុងគ្រួសារ។ ប្រសិនបើហាណា និងយ៉ូហានគីមមិន

បានថ្វាយព្រះនាងម៉ារីទៅព្រះជាម្ចាស់ ប្រហែលព្រះនាងម៉ារីមិនបានស្គាល់ព្រះអង្គទេ។ នៅថ្ងៃដែលទេវទូតកាព្រីអែលបានជួបជាមួយព្រះនាងម៉ារី ប្រសិនបើគ្មានហាណា និងយ៉ូហានគីម ព្រះនាងម៉ារីឥតមានសមត្ថភាព ដើម្បីឆ្លើយតបថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះម្ចាស់ចុះ**"។ ដូច្នេះ ជំនឿគាត់បានទទួលពីព្រះជាម្ចាស់មែន ប៉ុន្តែនៅក្នុងក្រុមគ្រួសាររបស់គាត់បានរីកចម្រើន រហូតដល់ព្រះនាងម៉ារីបានភ្ជាប់ជាមួយព្រះជាម្ចាស់ និងព្រះអង្គបានជ្រើសរើសព្រះនាងម៉ារីធ្វើជាមាតារបស់ព្រះយេស៊ូ។ ជំនឿជាអំណោយទានពិតមែន ប៉ុន្តែការថែរក្សាជំនឿត្រូវតែបន្តនៅក្នុងក្រុមគ្រួសារ ដែលយកចិត្តទុកដាក់ជាមួយកូនដើម្បីឲ្យស្គាល់ព្រះជាម្ចាស់ដែលជាព្រះបិតា ដើម្បីស្គាល់ព្រះយេស៊ូដែលជាព្រះបុត្រា និងដើម្បីរស់នៅក្នុងសេចក្ដីសុខដែលមកពីព្រះហឫទ័យព្រះជាម្ចាស់ផ្ទាល់។

ខ្ញុំជឿថា ពេលម្ដាយស្ដាប់លឺព្រះគម្ពីរដំណឹងល្អថ្ងៃនេះពិបាកចិត្ត ប្រសិនបើកូនមិនព្រមទទួលស្គាល់ម្ដាយបង្កើត តើម្ដាយមានអារម្មណ៍យ៉ាងណា? នៅពេលសាវ័កទៅប្រាប់ព្រះយេស៊ូថា ម្ដាយរបស់លោករកលោក ហើយព្រះអង្គឆ្លើយថា តើអ្នកណាជាម្ដាយរបស់ខ្ញុំ? នេះណែនាំឲ្យម្ដាយឈឺចិត្ត ដោយសារម្ដាយនិងកូនភ្ជាប់គ្នានៅក្នុងរបៀបពិសេស តាំងពីថ្ងៃចាប់កំណើតនៅក្នុងផ្ទៃពោះរហូតដល់ថ្ងៃចុងក្រោយនៃជីវិត។ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា "**អស់អ្នកដែលធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ អ្នកនោះជាបងប្អូននិងជាម្ដាយរបស់ខ្ញុំ**" នៅពេលនោះព្រះយេស៊ូដូចជាបានណែនាំឲ្យយើងទទួលក្រុមគ្រួសារថ្មីមួយ។ ក្រុមគ្រួសាររបស់យើងមិនមែនតែឪពុកម្ដាយកូនបង្កើត ប៉ុន្តែក្រុមគ្រួសារទៅជាគ្រួសារទូលំទូលាយ គឺជាបងប្អូនទាំងអស់ដែលជឿលើព្រះជាម្ចាស់ គឺបងប្អូនទាំងអស់ដែលយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចាប់ពីពេលនេះតទៅ ពេលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ យើងអាចនិយាយថាពិតមែនព្រះសហគមន៍ទៅជាក្រុមគ្រួសាររបស់យើង។ ព្រះយេស៊ូបានណែនាំឲ្យយើង ដែលជាគ្រីស្ដបរិស័ទរស់នៅក្នុងក្រុមគ្រួសារបង្កើតចូលនៅក្នុងក្រុមគ្រួសារមួយទូលំទូលាយ គឺព្រះសហគមន៍របស់យើងផ្ទាល់។ អគ្គសញ្ញាជ្រមុជទឹកមិនមែនណែនាំឲ្យយើងលាងពីអំពើបាបបាន មិនមែនណែនាំឲ្យយើងជម្រះចិត្តគំនិតរបស់យើងតែប៉ុណ្ណឹង ប៉ុន្តែអគ្គសញ្ញាជ្រមុជទឹកណែនាំឲ្យយើងចូលយ៉ាងពេញលក្ខណៈនៅក្នុងព្រះសហគមន៍ដែលជាព្រះកាយព្រះគ្រីស្ដ នៅក្នុងក្រុមគ្រួសារថ្មីមួយយ៉ាងពិសេសបំផុតដែលណែនាំឲ្យយើងភាពកក់ក្ដៅ ណែនាំឲ្យយើងទទួលសេចក្ដីសុខសាន្តយ៉ាងពិតប្រាកដ។ នេះជាមោទនភាពរបស់យើង ដោយសារអគ្គសញ្ញាជ្រមុជទឹកពិតមែនយើងទទួលជីវិតថ្មី ពិតមែនអំពើបាបរបស់យើងដូចជាលាងអស់ហើយ យើងទទួលក្រុមគ្រួសារថ្មីយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ ប្រសិនបើយើងយល់នេះ ជីវិតរបស់យើងលែងជាជីវិតចង្អៀតចង្អល់ តែជាជីវិតដែលភ្លឺស្វាងមែនទែន។ សព្វថ្ងៃនៅក្នុងភូមិភាគភ្នំពេញ យើងមានចាស់ៗដែលបានដើរតាមព្រះយេស៊ូ

ដោយសារនៅក្នុងព្រះសហគមន៍ គេបានរកឃើញគ្រួសារមួយដែលស្រឡាញ់គេ ជីវិតរបស់គេឯកាមែនទែន ប៉ុន្តែគេរកឃើញនៅក្នុងព្រះសហគមន៍ជាក្រុមគ្រួសារមួយដែលស្រឡាញ់គេ ដែលលើកទឹកចិត្តគេ ដែលណែនាំឲ្យដើម្បីធ្វើដំណើរទៅមុខ។

បងប្អូនដែលជាគ្រូអប់រំជំនឿ ឲ្យយើងយកចិត្តទុកដាក់ពិតមែនបន្តជំនឿដោយឲ្យចំណេះដឹង សំខាន់បំផុតធ្វើដូចម្ដេចដើម្បីណែនាំឲ្យបងប្អូន ដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងកូនក្មេងដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកពីក្មេងមក ឲ្យគេស្គាល់ព្រះយេស៊ូយ៉ាងពិតប្រាកដមែន មានន័យថាឲ្យគេបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូពិតៗ។ ដោយសារចំណេះដឹងយើងអាចទទួលប៉ុន្មានក៏បាន ជំនឿយើងស្វែងយល់បាន ប៉ុន្តែទំនាក់ទំនងផ្ទាល់ជាមួយព្រះយេស៊ូជាអ្វីដែលសំខាន់ជាងគេ។ ដូចលោកឪពុកលូកា គាត់បាននិយាយថា ពេលគាត់នៅក្មេងគាត់សប្បាយចិត្តក្នុងការដុតទៀននៅក្នុងព្រះវិហារ ហើយគាត់ឃើញលោកតាគាត់លុតជង្គង់នៅមុខទូព្រះកាយ គាត់មិនដឹងថាមានអ្វីនៅក្នុងទូព្រះកាយនោះ នេះជាជំហានទីមួយដើម្បីបង្កើតទំនាក់ទំនង ក្នុងនេះអត់មានចំណេះដឹងទេ ក្នុងនេះមានតែសក្ខីភាពនៃជំនឿ។ នេះជាសក្ខីភាពជាក់ស្ដែងដែលណែនាំឲ្យយើងយល់ថាព្រះយេស៊ូមានជីវិតរស់នៅ ព្រះយេស៊ូណែនាំឲ្យយើងមានជីវិតថ្មីដោយសារព្រះយេស៊ូធ្វើដំណើរជាមួយយើងសព្វថ្ងៃ។ ចំណុចមួយទៀត សម្រាប់យើងជាគ្រូអប់រំជំនឿឲ្យយើងធ្វើដូចម្ដេចដើម្បីកសាងព្រះសហគមន៍របស់យើង ដែលជាគ្រួសារយ៉ាងពិតប្រាកដមែន។ ដោយសារសង្គ្រាម សព្វថ្ងៃយើងមានយុវជនយុវនារីយ៉ាងច្រើនដែលខ្វះការលើកទឹកចិត្តពីឪពុកម្ដាយ យើងមានឪពុកម្ដាយមួយចំនួនធំគេទៅថៃអស់ហើយ គេខ្វះឪពុកម្ដាយដែលផ្ដល់ភាពកក់ក្ដៅ ព្រះសហគមន៍អាចធ្វើបានដែរព្រះសហគមន៍ត្រូវតែនឹកឃើញថា ពិតមែនយើងជាបងប្អូនគ្នា។ ព្រះសហគមន៍ជាឪពុកម្ដាយ ដូចព្រះបិតាជាឪពុកម្ដាយរបស់យើង ព្រះសហគមន៍ជាឪពុកម្ដាយដែលថែរក្សា លើកទឹកចិត្ត គោរព ស្រឡាញ់ យើងរួមគ្នាដើម្បីឲ្យព្រះសហគមន៍ទៅជាកន្លែងមួយ ដែលអាចរកឃើញគ្រួសារយ៉ាងពិតប្រាកដ ដែលណែនាំឲ្យយើងកក់ក្ដៅ ណែនាំឲ្យយើងមានសេចក្ដីសង្ឃឹម និងណែនាំឲ្យយើងទៅមុខនៅក្នុងជីវិតរបស់យើង។ ចុងក្រោយកុំឲ្យក្រុមគ្រួសារហ្នឹងទៅជាក្រុមគ្រួសារចង្អៀតចង្អល់ ឲ្យយើងប្រយ័ត្នដោយសារព្រះសហគមន៍របស់យើងកើតថ្មីយើងមានក្រុមយុវជន ក្រុមសង្គហៈ ក្រុមពិធីបុណ្យ... យើងមានគ្នាតិចណាស់ ដូច្នេះយើងកក់ក្ដៅគ្នាយើង យើងបានបង្កើតទំនាក់ទំនងសប្បាយគ្នាយើង។ ប៉ុន្តែគ្រួសារដ៏សុខសាន្តដែលមានឪពុកម្ដាយនិងកូន ជាគ្រួសារដែលបើកទ្វារ ដែលចេះមើលឃើញសេចក្ដីត្រូវការនៅក្នុងសង្គម។ ដូច្នេះព្រះសហគមន៍យើងក៏ដូចគ្នាដែរ កុំឲ្យយើងជាក្រុមគ្រួសារដែលទទួលភាពកក់ក្ដៅពីគ្នាទៅវិញទៅមកតែគ្នាយើង ឲ្យយើងទទួលមនុស្សថ្មី។ យើងត្រូវធ្វើឲ្យក្រុមគ្រួសាររបស់យើងជាក្រុមគ្រួសារដែលបើកទ្វារទូលំទូលាយ ដើម្បីទទួលស្វាគមន៍ថែមទៀតនិងថែមទៀតជា

ពិសេសអ្នកតូចតាចដែលគ្មានទីពឹង។ នឹកឃើញដល់បងប្រុសធារី ដែលគាត់បានបង្កើតក្រុមគ្រួសារមួយដោយទទួលមនុស្សដែលសង្គមមើលមិនឃើញ គាត់ណែនាំឲ្យកូនក្មេងពិការទាំងនោះពោរពេញដោយសេចក្តីសុខសាន្ត ដោយសារគេរស់នៅក្នុងក្រុមគ្រួសារដែលទូលំទូលាយដែលចេះបើកទ្វារជានិច្ច។

យើងអធិដ្ឋាន ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាក្រុមគ្រួសារដ៏វិសុទ្ធ ដែលមានព្រះនាងម៉ារី លោកយ៉ូសែប និងព្រះកុមារយេស៊ូ ដែលជាគំរូយ៉ាងពិសេសដើម្បីបំភ្លឺយើងថែមទៀត។ អាម៉ែន៕